**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខៈ ០១៨៦/១៩ ក.អ.ជ

ថ្ងៃច័ន្ទ ១០កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៩

# របាយការណ៍
# វឌ្ឍនភាពការងារប្រចាំខែមករា ឆ្នាំ ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## I. សេចក្តីផ្តើម

ខែមករា ដើមឆ្នាំ ២០១៩ នេះ ការអភិវឌ្ឍន៍ផែនការសកម្មភាពនៅតាមតំបន់ជនបទ នៅមានកម្រិតតិចតួចនៅឡើយ ។ ក្រសួងបានបញ្ចប់សន្និបាតបូកសរុបការងារឆ្នាំ ២០១៨ និងលើកទិសដៅការងារឆ្នាំ ២០១៩ ប្រកបដោយជោគជ័យ ។ ការងារស្ថាបនា ជួសជុលហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទកំពុងបន្តសកម្មភាពពីឆ្នាំចាស់ ស្របនឹងសកម្មភាពថ្មីដែលបានកំណត់ក្នុងផែនការឆ្នាំ ។ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា រួមទាំងអង្គការមិនមែនរដ្ឋាភិបាលផង នៅបន្តសកម្មភាពដដែល ។ សមិទ្ធផលសម្រេចបានក្នុងខែមករា ឆ្នាំ ២០១៩ មានដូចខាងក្រោម៖

## II. អំពីការងារគ្រប់គ្រងរបស់ក្រសួង

### ១. ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ខែមករា ឆ្នាំ ២០១៩ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៨១៦ នាក់ ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែធ្នូ ឆ្នាំ ២០១៨ មានការថយចុះចំនួន ១៣ នាក់។ ក្រសួងបានទទួលលិខិតចូលចំនួន ៦៧ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ៦៤ ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានា ចំនួន ០៨ ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ១២៣ ច្បាប់ ។

### ២. ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

ក្នុងខែមករា ឆ្នាំ២០១៩ លេខាធិការដ្ឋានទទួលបានសំណើ សំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានតាមរយៈវេទិកាសាធារណៈថ្នាក់ជាតិសរុប ចំនួន ០៨ ករណី ដែលក្នុងនោះបានដោះស្រាយជូនប្រជាពលរដ្ឋបានចំនួន ០៣ ករណី ។

### ៣. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងខែមករា ឆ្នាំ ២០១៩ ក្រសួងបានអនុវត្តចំណាយ ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៩ សម្រេច៖

- ចំណាយចរន្តអនុវត្តបានចំនួន ១ ០១៩ ២៤១ ៦៤០ រៀល ស្មើនឹង ០,៧៨% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ០០ រៀល ។

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

## ៤. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- ចូលរួមប្រជុំស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ លើការងារផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិ និងគ្រោងបញ្ចូលការងារនេះក្នុងថវិកាកម្មវិធីឆ្នាំ ២០២០
- ប្រជុំពិភាក្សាជាមួយអង្គការសមាគមន៍សម្របសម្រួល និងអភិវឌ្ឍន៍សង្គមនៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមកិច្ចប្រជុំគណៈកម្មការពិគ្រោះយោបល់លើកទី១ ស្តីពីផលប៉ះពាល់នៃកម្មវិធីប្រែប្រួលអាកាសធាតុនៅកម្ពុជា ទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ និងយេនឌ័រ
- ចុះណែនាំពីការធ្វើអង្កេតទិន្នន័យអភិវឌ្ឍន៍ជនបទ និងពង្រឹងស្ថិតិ នៅខេត្តក្រចេះ និងខេត្តសៀមរាប
- ចុះណែនាំលើការរៀបចំឯកសារផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០២០-២០២២ នៅខេត្តសៀមរាប និងខេត្តមណ្ឌលគិរី
- ចូលរួមកិច្ចប្រជុំ ស្តីពីសេចក្តីព្រាងលើតារាងសំនួរអង្កេតចន្លោះជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ
- រៀបចំ និងចងក្រងសៀវភៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៩-២០២៣ ដោយមានការចូលរួមពិនិត្យ និងផ្តល់យោបល់ ពីនាយកដ្ឋានជំនាញ និងថ្នាក់ដឹកនាំក្រសួងជាបន្តបន្ទាប់
- ចុះតាមដានការអនុវត្តថវិកាកម្មវិធីនៅខេត្តចំនួន ០២ គឺ ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ
- បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការគណៈកម្មាធិការមិត្តភាព ម៉ិនណូណៃច៍ ( Mennonite Center Committee )
- បានផ្តល់លិខិតអន្តរាគមន៍ដើម្បីនាំចូលរថយន្តចំនួន០១គ្រឿង ដោយពន្ធជាបន្ទុករបស់រដ្ឋជូនអង្គការហ្គូតនេប៊ឺកម្ពុជា ( Good Neighbors Cambodia )
- ចូលរួមវេទិកាស្តីពីភាពជាដៃគូរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ ។

## ៥. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ចូលរួមកិច្ចប្រជុំ ស្តីពីការរៀបចំរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពប្រចាំត្រីមាសទី៤ និងប្រចាំឆ្នាំ ២០១៨ គាំទ្រកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមកិច្ចប្រជុំពិភាក្សាលើការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្តីពីការរៀបចំផែនការសកម្មភាពដំណាក់កាលទី៣ ឆ្នាំ ២០១៩ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កែសម្រួលផែនការសកម្មភាពដំណាក់កាលទី៣ (MAP3) ឆ្នាំ ២០១៩

### ៦. ការងារអធិការកិច្ច និងសវនកម្ម

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការឆ្នាំ២០១៨
- ចូលរួមកិច្ចប្រជុំ ស្តីពីការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

## III. សកម្មភាពការងារជំនាញ

### ១. ការងារអភិវឌ្ឍន៍ផ្លូវជនបទ

- គម្រោងសាងសង់ ជួសជុលផ្លូវ និងសំណង់សិល្បការ្យ ឆ្នាំ២០១៨ ជំពូក២១ មាន១០៥ គម្រោងកំពុងបន្តដំណើរការការដ្ឋានបានចំនួន ១០៣គម្រោង លទ្ធផលគិតជាមធ្យមស្មើនឹង ៨៤ % ក្នុងនោះមាន ៖
  - ផ្លូវកៅស៊ូប្រវែង ៨២,៣៥ គ.ម
  - ផ្លូវបេតុងប្រវែង ៦,៧៤៤ គ.ម
  - ផ្លូវក្រាលក្រួសក្រហមប្រវែង ៣៨៧,៨៦ គ.ម
  - សំណង់លូមូល លូជ្រុង ៥៦៤ កន្លែង
  - ស្ពានបេតុងចំនួន ២៦ កន្លែង ប្រវែង ១៣១១ម
- ការងារថែទាំខួប ប្រចាំ និងជួសជុលបន្ទាន់ឆ្នាំ ២០១៩ កំពុងដំណើរការនីតិវិធី ។

### ២. ការងារផ្គត់ផ្គង់ទឹកជនបទ

- បានខួងអណ្តូងជូនកងពលតូចទ័ពធំត្រយោង និងគ្រួសារទ័ពចំនួន ០២ អណ្តូង នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយគម្រោងឧបត្ថម្ភធនដល់គ្រួសារក្រីក្រ គ្មានលទ្ធភាពតបណ្តាញទឹកស្អាត នៅស្រុកពោធិ៍រៀង ខេត្តព្រៃវែង និងស្រុកល្វាឯម ខេត្តកណ្តាល ។

### ៣. ការងារថែទាំសុខភាព និងអនាម័យជនបទ

- បានជ្រើសរើសភូមិគោលដៅអនុវត្តគម្រោងជំរុញការផ្តល់សេវាអនាម័យជនបទឆ្នាំ២០១៩
- បានចូលរួមកិច្ចប្រជុំពិភាក្សាជាមួយអង្គការ EMW អំពីកម្មវិធីបង្គន់អនាម័យ Sato pan នៅខេត្តព្រៃវែង
- បានចូលរួមសិក្ខាសាលាណែនាំស្តីពីការគាំទ្រក្រុមការងារថ្នាក់ខេត្តលើគម្រោងលើកកម្ពស់អនាម័យ CRSHIP នៅខេត្តកំពង់ឆ្នាំង ព្រៃវែង កំពត កំពង់ធំ និងខេត្តក្រចេះ
- បានចូលរួមប្រជុំផ្លាស់ប្តូរបទពិសោធន៍ ការអនុវត្តកម្មវិធីអនាម័យតាមសាលារៀននៅស្រុកចិត្របុរី ខេត្តក្រចេះ
- បានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសអំពីការពិនិត្យផ្ទៀងផ្ទាត់ផ្ទៃក្នុង ភូមិ ODF ទៅដល់មន្ត្រីអង្គការ iDE ។ គោលបំណងគឺផ្តល់ចំណេះដឹងអំពីរបៀបផ្ទៀងផ្ទាត់ផ្ទៃក្នុងភូមិ ODF និងរៀបចំក្រុមការងារផ្ទៀងផ្ទាត់ ។

### ៤. ការងារអភិវឌ្ឍន៍សហគមន៍

- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានរៀបចំឯកសារ និងកំណត់ឃុំគោលដៅសម្រាប់ផ្សព្វផ្សាយបើកវគ្គសិក្សាថ្មី ឆ្នាំ២០១៩
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានចុះផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនទាំងក្នុង និងក្រៅមជ្ឈមណ្ឌល តាមរយៈការចែកសេចក្តីជូនដំណឹងដល់មេភូមិចំនួន ២៨ ភូមិ នៅក្នុងឃុំញ៉ែងញ៉ង ស្រុកទ្រាំង និងឃុំស្រែរនោង ស្រុកត្រាំកក់ ។

### ៥. ការងារបណ្តុះបណ្តាល

- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ៤៣នាក់ ក្នុងនោះស្រីចំនួន ០៥នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ២៥ នាក់ ក្នុងនោះស្រីចំនួន ០៥ នាក់
- បានផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីវគ្គបណ្តុះបណ្តាល ចំនួន ០៣លើក
- បានរៀបចំឯកសារចាត់បញ្ជូនមន្ត្រីដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាល ចំនួន ០១លើក
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង បានចុះតាមដានសិក្ខាកាមបញ្ចប់វគ្គសំអាងការស្ថិតនៅក្នុងឃុំរោងដំរី ស្រុកបាភ្នំ និងនៅសង្កាត់កំពង់លាវ ក្រុងព្រៃវែង ដែលបានបើកហាងដោយខ្លួនឯង និងទទួលបានជោគជ័យដោយរកចំណូលបានចាប់ពី ២៥០$-៣០០$ ក្នុងមួយខែ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀងបានចុះតាមដាន និងវាយតម្លៃសិក្ខាកាមបញ្ចប់វគ្គជួសជុលម៉ាញ៉េ ទូរទស្សន៍ និងវិទ្យុ ស្ថិតនៅក្នុងស្រុករមាសហែក ដែលបានបើកហាងដោយខ្លួនឯង
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានចុះសំណេះសំណាលជាមួយសិក្ខាកាមបញ្ចប់វគ្គចំនួន ០២នាក់ នៅស្រុកកំពង់សៀម និងស្រុកបាធាយដែលបានបើកហាងដោយខ្លួនឯង
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនវគ្គថ្មី សម្រាប់ឆ្នាំ២០១៩
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ បានរៀបចំឯកសារដើម្បីធ្វើផែនការថវិកាចំណាយ និងធ្វើការផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនវគ្គថ្មី សម្រាប់ឆមាសទី១ ឆ្នាំ២០១៩
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពត បានផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនតាមវគ្គនីមួយៗ ស្ថិតនៅឃុំព្រែកត្នោត ស្រុកទឹកឈូ និងឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ។

### ៦. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់បានផ្តល់ឥណទានសរុបចំនួន ៤ ៥០០ ៥៩៦ ២៣៥ រៀល (បួនប៊ីលានប្រាំរយលានប្រាំរយកៅសិបប្រាំមួយពាន់ពីររយសាមសិបប្រាំរៀល)ស្មើនឹង ១ ១៤៤ ៣៧៥,០២ ដុល្លារអាមេរិក (មួយលានមួយរយសែសិបបួនពាន់បីរយចិតសិបប្រាំដុល្លារនិង

ពីរសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៥ ០៩០ នាក់នៅភូមិគោលដៅ ចំនួន ២០៩ភូមិ ៨៤ឃុំ ៣៥ស្រុក ក្នុងខេត្តគោលដៅចំនួន១៥ ។

**៧. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច**

- ចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យឡើងវិញលើការងារកំណត់អត្តសញ្ញាណសហគមន៍ជនជាតិភាគតិចជង ចំនួន ០៥ សហគមន៍ នៅតំបន់អារ៉ែង ខេត្តកោះកុង ដែលមានភាពយឺតយ៉ាវនៅថ្នាក់ក្រោមជាតិ
- បានចូលរួមកិច្ចប្រជុំ ស្តីពីការបង្កើតក្រុមការងារដឹកនាំ និងអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិភាគតិច ជាមួយអង្គការដៃគូ (CIPO, CIYA)
- ទំនាក់ទំនងជាមួយអង្គការដៃគូ និងក្រសួងពាក់ព័ន្ធដើម្បីរៀបចំធ្វើផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិចតាមបណ្តាខេត្តទាំង ១៥ ។

**៨. ការងារយេនឌ័រ**

- បានចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពី លក្ខន្តិកៈរបស់បណ្តាញសហគ្រិនស្ត្រីកម្ពុជា
- បានរៀបចំសិក្ខាសាលាស្តីពីការ ផ្សព្វផ្សាយទស្សនៈយេនឌ័រ អនុសញ្ញាស៊ីដ (CEDAW ) និងអនុសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅមន្ទីអភិវឌ្ឍន៍ជនបទខេត្តតាកែវ និងខេត្តកំពត ។

**៩. ការងារប្រយុទ្ធនឹងជំងឺអេដស៍**

- បានរៀបចំប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០១៩ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

**១០. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ**

- បានចូលរួមសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងផែនការថវិកា ឆ្នាំ២០១៩ របស់ គ.ជ.អ.ប ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ប្រជុំត្រួតពិនិត្យ និងស្តាប់របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៨ របស់ គ.ជ.អ.ប លើកកម្មវិធីអនាម័យលើស្រុកទាំង១៥ ។

## IV. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការផ្សេងៗ

**១. គម្រោងកែលម្អផ្លូវជនបទ ជំហាន ២**

អនុវត្តក្នុងខេត្តគោលដៅចំនួន១០ គឺ ខេត្តត្បូងឃ្មុំ កំពង់ចាម តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ គិតត្រឹមដំណាច់ខែមករានេះ គម្រោងសម្រេចបាន ៖

- ខេត្តត្បូងឃ្មុំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១៩៣,៩ គ.ម សម្រេចបាន៨៩,៤៩%
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១០៤,០៨គ.ម សម្រេចបាន ៣៧,៧៦%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៤២,១៧%

- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១២៦,៣០គ.ម សម្រេចបាន ៣៨,៨១%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ខ្សែប្រវែង ១១៣,៤០គ.ម សម្រេចបាន ២៩,៨៤%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ១៤,៥៦%
- ខេត្តពោធិ៍សាត់ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១២៥,៥០គ.ម សម្រេចបាន ៨៣,៩២%
- ខេត្តបាត់ដំបង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៨ខ្សែ មានប្រវែងសរុប ១០១,២០គ.ម សម្រេចបាន ៨៥,៩៩%
- ខេត្តបន្ទាយមានជ័យ :បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ខ្សែ មានប្រវែងសរុប ៩០,៧០ គ.ម សម្រេចបាន ៨២,០៤%
- ខេត្តកំពង់ចាម : បាន និងកំពុងដំណើរការសាងសង់ផ្លូវក្រាលបេតុងចំនួន ០៦ខ្សែ មានប្រវែងសរុប ៥០គ.ម សម្រេចបាន ៩៣,០២% ។

**២. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំហានទី ៦**

គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំហានទី ៦ ជាគម្រោងសហហិរញ្ញប្បទានឥតសំណងរវាងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារ KfW និងរាជរដ្ឋាភិបាលកម្ពុជា អនុវត្តនៅខេត្តបន្ទាយមានជ័យ ។ អង្គភាពគ្រប់គ្រងគម្រោងសហការជាមួយក្រុមហ៊ុន GOPA Consultant បាន និងកំពុងរៀបចំនីតិវិធីដេញថ្លៃ ដែលគ្រោងនឹងចុះកិច្ចសន្យានៅខែកុម្ភៈ ឆ្នាំ២០១៩ ។

**៣. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គម្រោងសាច់ប្រាក់ពលកម្ម សម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ មានរយៈពេល ០៣ឆ្នាំ និងផ្តោតលើការស្តារ និងកែលំអផ្លូវជនបទប្រវែងប្រមាណ ៦៨៧គីឡូម៉ែត្រ ដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ១២ គឺ ខេត្តកណ្តាល តាកែវ ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ស្ពឺ ព្រៃវែង និងខេត្តឧត្តរមានជ័យ ។ គម្រោងបាន បញ្ចប់ការវាស់វែងចំនួន ៥០០ គម្រោង ប្រវែងសរុប ៥២៦ ៧៧១ ម៉ែត្រ។

**៤. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី ២**

- បានសាងសង់បង្គន់តាមខ្នងផ្ទះ ចំនួន ២៦បង្គន់ នៅខេត្តតាកែវ
- បានចុះស្រង់ឈ្មោះគ្រួសារដែលទទួលបានបង្គន់គម្រោង ABC និងគ្រួសារដែលទទួលបានកំបោរ នៅឃុំគោកដូង ស្រុកសូទ្រនិគមន៍ ឃុំចាន់សរ ស្រុកអង្គរជុំ ខេត្តសៀមរាប
- បានចូលរួមកិច្ចប្រជុំជាមួយមន្ត្រីអង្គភាពសម្របសម្រួលគម្រោង និងទីប្រឹក្សា ស្តីពីការត្រួតពិនិត្យតាមដានការអនុវត្តគម្រោងកញ្ចប់ទី៥ និងកញ្ចប់ទី៦ ព្រមទាំងចុះពិនិត្យដល់ទីតាំងអនុវត្តគម្រោង ។

## ៥. គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទក្រោមហិរញ្ញប្បទានឥតសំណងរបស់សាធារណៈរដ្ឋ ប្រជាមានិតចិន

គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទ ដំហាន ១ ក្រោមហិរញ្ញប្បទានឥតសំណងរបស់សាធារណៈរដ្ឋប្រជាមានិតចិន ដោយផ្តោតលើសកម្មភាពធំៗចំនួនពីរ គឺ ការផ្គត់ផ្គង់ទឹកជនបទ ដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ០៦ គឺ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ កណ្តាល ត្បូងឃ្មុំ និងខេត្តស្វាយរៀង និងការកែលម្អផ្លូវជនបទ ដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ០៤ គឺ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ និងខេត្តកំពង់ចាម ។ គិតត្រឹមខែមករានេះ គម្រោងសម្រេចបាន៖

- បាន និងកំពុងសាងសង់ផ្លូវចំនួន ០៧ ខ្សែ ប្រវែង ៣៥,៥ គ.ម ក្នុងខេត្តគោលដៅទាំង ០៤ សម្រេចបាន ៩០,១៦ %
- បានសាងសង់ស្ពានបេតុង ចំនួន ០១ ប្រវែង ១២៥ ម៉ែត្រ នៅខេត្តកំពង់ស្ពឺ សម្រេច ១០០%។

## ៦.គម្រោងអភិវឌ្ឍន៍សហគមន៍ចម្រុះតាមដងទន្លេមេគង្គ

គម្រោងនេះជាជំនួយហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលចិនក្នុងក្របខណ្ឌមេគង្គឡានឆាងសម្រាប់ឆ្នាំ ២០១៨ អនុវត្តលើការងារសហគមន៍ចម្រុះនៅខេត្តជាប់ដងទន្លេមេគង្គចំនួន ០៤ គឺ ខេត្តកណ្តាល ព្រៃវែង ក្រចេះ និងខេត្តស្ទឹងត្រែង ។ ក្នុងខែមករា នេះ គម្រោងសម្រេចបាន ៖

- បានចុះពិនិត្យ និងវាយតម្លៃសមិទ្ធផលគម្រោងនៅខេត្តគោលដៅ
- កំពុងជីកប្រឡាយទឹក ០១ ខ្សែ ប្រវែង ៣៥០ម
- សាងសង់បង្គន់ចំនួន ០៥ បង្គន់
- ផ្តល់ពាងស្តុងទឹកចំនួន ១២កន្លែង ។

## V. សេចក្តីសន្និដ្ឋាន

ខែមករា ដើមឆ្នាំ២០១៩ នេះ ការអនុវត្តន៍ផែនការសកម្មភាពរបស់ក្រសួងទាំងមូលនៅមានចំនួនតិចតួចនៅឡើយ សកម្មភាពដែលលេចធ្លោនោះគឺក្រសួងបានធ្វើសន្និបាតបូកសរុបការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ ២០១៩ ក្រោមអធិបតីភាព **ឯកឧត្តម យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រីប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។ សន្និបាតបានកំណត់ទិសដៅអាទិភាពចំនួន ០៤ ទាក់ទងនឹងការពង្រឹងស្ថាប័ន ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស ការស្ថាបនា ជួសជុល លើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គមនាគមន៍ និងសេវាសាធារណៈ ការលើកកម្ពស់សុខភាព ការអប់រំ និងលក្ខខណ្ឌនៃការរស់នៅ ការបង្កើតការងារ មុខរបរ សហគ្រិនភាព និងសកម្មភាពសេដ្ឋកិច្ច ដើម្បីបន្តការអភិវឌ្ឍន៍ជនបទនៃព្រះរាជណាចក្រកម្ពុជាឲ្យទទួលបានការរីកចម្រើនទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

សមិទ្ធផលបានបង្ហាញពីវឌ្ឍនភាពជាច្រើនដែលក្រសួងសម្រេចបានទាក់ទងដល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសេវាសាធារណៈផ្សេងៗនៅតាមតំបន់ជនបទ ដូចជាផ្លូវថ្នល់ជនបទ ស្ពាន សំណង់សិល្បការ្យ ស្រះទឹក អណ្តូងទឹក បង្គន់អនាម័យ ព្រមទាំងការអប់រំសុខភាពអនាម័យតាមសហគមន៍ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋាន បាន និងកំពុងចូលរួមលើកកម្ពស់កម្រិតជីវភាព គុណភាព និងគុណតម្លៃនៃជីវិតរបស់ប្រជាជននៅជនបទកាន់តែប្រសើរឡើង ក្នុងការចូលរួមអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចក្នុងក្របខណ្ឌវិស័យអភិវឌ្ឍន៍ជនបទ ៕

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**